# កម្ពុជា៖ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន
# ការវាយតំលៃពាក់កណ្ដាលគម្រោង៖ របាយការណ៍បញ្ចប់
## សង្ខេប


គណៈកម្មាការជាតិដើម្បីការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅលំដាប់ថ្នាក់ក្រោមជាតិ បានផ្ដល់កិច្ចសន្យាទីប្រឹក្សាមួយក្រុមដើម្បីធ្វើការវាយតម្លៃពាក់កណ្ដាលគម្រោង នៃគម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ។ ការវាយតម្លៃនេះ មានគោលបំណងកំណត់ដំណើរការ និងស្វែងរកអនុសាសន៍ធ្វើការកែសម្រួលដល់គម្រោង និងផ្ដល់មេរៀនសំរាប់ការគាំទ្ររបស់ធនាគារពិភពលោក ។ ការវាយតម្លៃធ្វើឡើងនៅក្នុងខែវិច្ឆកា និងខែធ្នូ ឆ្នាំ២០០៩ ដែលនៅក្នុងនោះមានការពិនិត្យឡើងវិញនូវឯកសារនានា ជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល និងម្ចាស់ជំនួយ នៅទីក្រុងភ្នំពេញ និងការចុះសិក្សានៅតាមខេត្តគោលដៅចំនួនបួន[1] ដែលតំណាងឱ្យតំបន់ភូមិសាស្ត្រសំខាន់ៗនៅកម្ពុជា ។ នៅតាមខេត្តទាំងនោះ ក្រុមការងារបានជួបជាមួយភ្នាក់ងារនានា រួមមាន រដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រធានភូមិ និងអ្នកភូមិ ។

គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន មានគោលបំណងចូលរួមចំណែកអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធជាអទិភាព និងផលប្រយោជន៍សាធារណៈផ្សេងទៀតដល់ថ្នាក់ឃុំ-សង្កាត់ និងតាមរយៈការពង្រឹងប្រព័ន្ធនៃការចូលរួមតាមលក្ខណៈវិមជ្ឈការរដ្ឋបាលមូលដ្ឋាន ។ ដំណាក់កាលទីមួយរបស់គម្រោង ជាឥណទានសមាគមន៍នៃការអភិវឌ្ឍន៍អន្តរជាតិ ដែលមានទឹកប្រាក់ចំនួន ២២លានដុល្លាសហរដ្ឋអាមេរិក សំរាប់រយៈពេលពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៧ រួមផ្សំជាមួយថវិកាបន្ថែម ដែលជាជំនួយគ្មានសំណងចំនួន ៣៦,២៥ លានដុល្លាសហរដ្ឋអាមេរិក ដែលចាប់ផ្ដើមពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១០ ។ គម្រោងនេះត្រូវបានអនុវត្តទាំងស្រុងតាមរយៈប្រព័ន្ធរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ទាំងប្រព័ន្ធនៃការគ្រប់គ្រង និងហិរញ្ញវត្ថុ) និងដោយពឹងផ្អែកទៅលើការគាំទ្ររបស់ទីប្រឹក្សាថ្នាក់ជាតិ ខេត្ត និងស្រុក ពីកម្មវិធីគាំទ្រការអភិវឌ្ឍន៍លិទ្ធិប្រជាធិតេយ្យតាមរយៈការធ្វើវិមជ្ឈការ និងសហវិមជ្ឈការ (PSDD) ដែលឧបត្ថម្ភថវិការដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃ ប្រទេសស៊ុយអែដ (Sida) និងនាយកដ្ឋាន


---

[1] ខេត្តទាំងបួនដែលបានធ្វើការវាយតម្លៃដោយក្រុមការងារមាន បាត់ដំបង កំពង់ធំ ក្រចេះ និងកំពត ។

អភិវឌ្ឍអន្តរជាតិ (DfID) ។ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន កំពុងអនុវត្តគម្រោងនៅឃុំ-សង្កាត់ទាំងអស់ឃុំ-សង្កាត់ និងស្រុក ទូទាំង ២៣ ខេត្ត (មិនបញ្ចូលរាជធានីភ្នំពេញ) និងចែកចេញជាពីរផ្នែកៈ

- ផ្នែកមួយៈ ផែនការមូលដ្ឋាន និងវិនិយោគ (ថ្នាក់ឃុំ-សង្កាត់)
- ផ្នែកពីរៈ គាំទ្រគោលនយោបាយ និងការគ្រប់គ្រងគម្រោង (ថ្នាក់ជាតិ និងខេត្ត) ។

ជាទូទៅ ក្រុមការវាយតម្លៃពាក់កណ្តាលគម្រោង ជឿជាក់ថា គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ជាគម្រោងមួយដ៏ប្រសើរដែលឈានមុខក្នុងការអភិវឌ្ឍន៍ជាក់ស្តែង ។ ហេតុផលដែលបានលើកឡើងនេះ រួមមានៈ

- គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន គាំទ្រដល់កម្មវិធីជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍គម្រោងនៅក្នុងខេត្តចំនួន ២៣ (ថវិកាឃុំ-សង្កាត់)
- គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ផ្សារភ្ជាប់ជាមួយប្រព័ន្ធ និងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា
- គម្រោងវិនិយោគជនបទ និងអភិបាលកិច្ច មូលដ្ឋាន គាំទ្រដល់កម្មវិធីជាតិដើម្បីអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិដែលនាំទៅដល់ការធ្វើវិមជ្ឈការ និងអភិបាលកិច្ច ទូទាំងប្រទេសកម្ពុជាសំរាប់រយៈ ១០ឆ្នាំ ខាងមុខ
- គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន គាំទ្រដល់មូលនិធិឃុំ-សង្កាត់ ដែលផ្តល់ដល់ឃុំសង្កាត់ និងអនុញ្ញាតឱ្យអ្នកដឹកនាំ និងប្រជាជនទទួលបានបទពិសោធន៍ លើការគ្រប់គ្រងគម្រោង និងកសាងអភិបាលកិច្ចល្អ ។

ការវាយតម្លៃត្រូវបានពិនិត្យលើចំណុចសំខាន់ៗនៃគម្រោង ដែលមានសង្ខេបលទ្ធផលដូចខាងក្រោម ដែលមានលក្ខណៈវិនិច្ឆ័យចំនួន ៥ៈ

## ១. ប្រសិទ្ធិភាព

គម្រោងវិនិយោគជនបទ និងអភិបាលកិច្ច មូលដ្ឋាន ទទួលបានការពេញចិត្ត ដូចចំណុចលើកឡើងខាងក្រោមៈ

- គម្រោងអនុវត្តតាមប្រព័ន្ធ និងរចនាសម្ព័ន្ធរាជរដ្ឋាភិបាលកម្ពុជា
- PSDD ផ្តល់ការគាំទ្រដល់ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន
- លទ្ធផលរបស់គម្រោងត្រូវបានបញ្ចប់ស្ទើរទាំងអស់
- មិនសូវមានការប្រើប្រាស់ធនធានខុសទិសដៅ ដោយសារមានបទដ្ឋានត្រឹមត្រូវ និងតឹងរឹង ចែងនៅក្នុងសៀវភៅណែនាំការអនុវត្តន៍គម្រោង (PIM) ។

បញ្ហាពាក់ព័ន្ធជាមួយប្រសិទ្ធិភាពគម្រោង ដោយសារពឹងផ្អែកលើទីប្រឹក្សាបច្ចេកទេស ប្រាក់ បៀវត្ស និងប្រាក់ឧបត្ថម្ភដល់មន្ត្រីរដ្ឋាភិបាល នៅទាប នេះហើយក៏ជាហេតុដែលធ្វើឱ្យមានភាគរយខ្ពស់នៃគម្រោង ហៅថារចនាសម្ព័ន មានគុណភាពទាប ដោយសារគ្មានការត្រួតពិនិត្យបច្ចេកទេសឱ្យបានជិតដល់ ទន្ទឹមនេះ សៀវភៅណែនាំអនុវត្តគម្រោង មានភាពស្មុគ្រស្មាញ ទាមទាឱ្យមន្ត្រីឃុំ-សង្កាត់ មានការងារច្រើនហួស ។

## ២. ស័ក្តិសិទ្ធិ

គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ទទួលបានការពេញចិត្ត ដូចចំណុចលើកឡើងខាងក្រោម:

- ប្រព័ន្ធត្រូវបានប្រើប្រាស់គ្រប់លំដាប់ថ្នាក់ដើម្បីដំណើរការសកម្មភាព មូលនិធិឃុំ-សង្កាត់
- ថវិកាដែលបានផ្តល់ឱ្យឃុំ-សង្កាត់តាមរយៈ មូលនិធិឃុំ-សង្កាត់ ផ្តល់ជាមធ្យោបាយ និងការលើកទឹកចិត្តដល់ប្រជាជនចូលរួមក្នុងដំណើរធ្វើផែនការ និងចូលរួមក្នុងការអភិវឌ្ឍន៍ឃុំ-សង្កាត់របស់ពួកគេ
- ផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំ មានសក្តានុពលសំរាប់ឆ្លុះបញ្ចាំងអទិភាពឃុំតាមរយៈដំណើរការធ្វើផែនការដោយមានការចូលរួម ហើយផែនការនេះត្រូវបានរៀបចំ និងបានប្រើប្រាស់ដើម្បីទាក់ទាញធនធានតាមរយៈសមាហរណកម្មផែនការស្រុក ។

បញ្ហាពាក់ព័ន្ធជាមួយភាពស័ក្តិសិទ្ធិរបស់គម្រោងមានៈ ផ្អែកលើដំណើរការតែមួយគត់ មិនអាចកសាងអភិបាលកិច្ច តែការងារអប់រំប្រជាពលរដ្ឋ និងដំណើរនៃការផ្តល់អំណាចក្នុងការអនុវត្តន៍សកម្មភាពមូលនិធិឃុំ-សង្កាត់ ប្រព័ន្ធត្រួតពិនិត្យតាមដានមិនទាន់មានទិន្នន័យគ្រប់គ្រាន់ និងប្រព័ន្ធសំរាប់វាស់វែងភាពស័ក្តិសិទ្ធីរបស់គម្រោង ល្បឿននៃការកែទម្រង់រដ្ឋាភិបាលមានដំណើរការយឺត ដោយសារមានការលំបាកពាក់ព័ន្ធ

ទៅនឹងការកំណត់មុខងារ និងធនធាននៅគ្រប់ស្រទាប់ជាន់ថ្នាក់ និងថវិកាសំរាប់ឃុំ-សង្កាត់ ស្តួចស្តើង មានន័យថាគម្រោងដែលមានសក្តានុពលផលប្រយោជន៍តិចតួច អាចត្រូវបានបញ្ចប់ ។

## ៣. ផលប៉ះពាល់

ផលប៉ះពាល់ ពីគម្រោង គឺការទទួលបានការពេញចិត្ត ដូចចំណុចលើកឡើងខាងក្រោមៈ

- ភាពក្រីក្រត្រូវបានថយចុះក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះ នៅគ្រប់ខេត្តទាំងអស់
- ការកាត់បន្ថយភាពក្រីក្រ ត្រូវទទួលបានជោគជ័យតាមរយៈការអនុគម្រោងហេថារចនាសម្ព័នឃុំ-សង្កាត់ និងការបន្តប្រតិបត្តិការនៃប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម
- ផលប្រយោជន៍ - ការសិក្សាលើតម្លៃ បានបង្ហាញថា ផលប្រយោជន៍ដែលបានបន្ថែមដោយគម្រោង អាចមានកំរិតគ្រប់គ្រាន់ដើម្បីធ្វើឱ្យមានផលវិជ្ជមានទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា
- វិមជ្ឈការត្រូវបានកើតឡើង ហើយគម្រោងកំពុងគាំទ្រដល់រាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រាកដថា តំរូវការទាំងបីសំរាប់វិមជ្ឈការលិទ្ធិប្រជាធិបតេយ្យ ដូចជា ធនធាន អំណាច និងយន្តការគណនេយ្យភាព ត្រូវបានផ្តល់ និងធ្វើឱ្យប្រសើរឡើងគ្រប់ពេលវេលា ។
- អភិបាលកិច្ចត្រូវបានធ្វើឱ្យប្រសើរឡើងនៅគ្រប់ស្រទាប់ថ្នាក់ដូចមានកសិណបង្ហាញដែលបានសំរេចប្រឈមនឹងចំណុចសំខាន់ទាំងប្រាំពីរនៃគម្រោងការអភិបាលកិច្ចល្អ[២] ។

បញ្ហាពាក់ព័ន្ធជាមួយផលប៉ះពាល់មានៈ កំណត់ផលប៉ះពាល់ទៅលើកិច្ចអន្តរាគមន៍ណាមួយ ដើម្បីពិនិត្យមើលថា តើអនុគម្រោងហេថារចនាសម្ព័ន ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងឃុំ-សង្កាត់ដល់កំរិតណា និងការប៉ះទង្គិចព័តិមានលើហេថារចនាសម្ព័នជនបទខ្នាតតូចនេះ ។

## ៤. ភាពចាំបាច់

ភាពចាំបាច់សំរាប់ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ទទួលបានការពេញចិត្តដោយសារហេតុផលដូចខាងក្រោមៈ

- គម្រោងស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររាជរដ្ឋាភិបាល និងធនាគារពិភពលោក

---

[2] ចំណុចសំខាន់ទាំងប្រាំពីរនៃអភិបាលកិច្ចល្អ មាន ១.ការដាក់ឱ្យដេញថ្លៃ ២.ការគ្រប់គ្រងហិរញ្ញវត្ថុ ៣.ការបើកចំហ ៤.សង្គមស៊ីវិល ៥.យន្តការប្តឹង និងដំណោះស្រាយ ៦.ការដាក់ទណ្ឌកម្ម និង ៧.គុណភាពបច្ចេកទេសនៃការរៀបចំប្លង់ និងសាងសង់ ។

- ចូលរួមចំណែកដើម្បីអភិវឌ្ឍជនបទ និងកាត់បន្ថយភាពក្រីក្រ ដែលជាអទិភាពនៃរាជរដ្ឋាភិបាលកម្ពុជា ។

បញ្ហានៅទីនេះ គឺខ្វះមធ្យោបាយដើម្បីរៀន និងចែករំលែកបទពិសោធន៍ ពីគម្រោងមួយទៅគម្រោងមួយទៀត ដែលប្រើប្រាស់វិសាស្រ្តផ្សេងៗគ្នាក្នុងការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ។

## ៥. និរន្តរភាព

និរន្តរភាពសំរាប់ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ទទួលបានការពេញចិត្ត ដោយសារហេតុផលដូចខាងក្រោមៈ

- ផ្សាភ្ជាប់ជាមួយ ស្ថាបន និង ប្រព័ន្ធរបស់រាជរដ្ឋាភិបាល
- កសាងសមត្ថភាពមន្រ្តីរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំឃុំ-សង្កាត់ និងប្រជាជន
- មូលនិធិឃុំ-សង្កាត់ពំពេញតំរូវការដល់ប្រជាជន តាមរយៈការផ្តល់ថវិកាដល់អនុគម្រោងដែលបានកំណត់ និងដាក់អទិភាពដោយមានការចូលរួមក្នុងដំណើរធ្វើផែនការ
- ធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការអនុវត្តន៍ការត្រួតពិនិត្យសុវត្ថិភាព (Safeguards) សំរាប់គម្រោងទាំងអស់
- មូលនិធិឃុំ-សង្កាត់ ត្រូវបានកសាងឡើងជាច្បាប់ និងអនុក្រិត្យ ក្នុងរយៈ៣ឆ្នាំម្តង ផ្តល់ការណែនាំលើសមាមាត្រនៃចំនូលថវិកាជាតិដែលត្រូវប្រើប្រាស់សំរាប់មូលនិធិឃុំ-សង្កាត់ នៅក្នុងលក្ខខណ្ឌមួយដែលភាគរយមិនត្រូវអាចបន្ថយចុះបានទេ ។

បញ្ហាសំខាន់ពាក់ព័ន្ធជាមួយនិរន្តរភាព ត្រូវពិចារណាលើតួនាទីរបស់ទីប្រឹក្សា និងប្រាក់ឧបត្ថម្ភដល់បុគ្គលិក ហើយថាតើមានវិធានការលើការចំណាយផ្សេងទៀតដែលស័ក្តិសិទ្ធិជាងនេះ ដើម្បីគាំទ្រ មូលនិធិឃុំ-សង្កាត់នាពេលអណាគត់ ។ កំរិតនៃការអប់រំ និងជំនាញរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងវិធីកសាងសមត្ថភាពរបស់ពួកគេ ក្នុងការគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ ។ ហើយបញ្ហាប្រាក់នៅទាបរបស់មន្រ្តីរដ្ឋាភិបាល និងតំរូវការរបស់មន្រ្តីរដ្ឋាភិបាលមានជំនាញ និងប្តេជ្ញាចិត្ត លើការគាំទ្រដល់ឃុំ-សង្កាត់ ឬមួយក៏ត្រូវប្រើប្រាស់ផ្នែក ឯកជនដើម្បីគាំទ្រដល់ការងារនេះ ។

ក្នុងការធ្វើការវាយតម្លៃនេះ ក្រុមការងារវាយតម្លៃពាក់កណ្តាលគម្រោង បានកំណត់ផ្នែកមួយចំនួន ដែលធ្វើឱ្យប្រសើរឡើង ដើម្បីពង្រឹង ការអនុវត្តន៍ លទ្ធផល និងផលប៉ះពាល់របស់គម្រោង ។ ហេតុនេះហើយ អនុសាសន៍ ត្រូវបានលើកឡើងនៅក្រោមចំណងជើងដូចតទៅនេះ:

- ការចូលរួម
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃ
- ការត្រួតពិនិត្យលើសុវត្ថិភាព
- ការគាំទ្របច្ចេកទេស
- មូលនិធិឃុំ-សង្កាត់អនុគម្រោង
- អភិបាលកិច្ច
- និរន្តរភាព

តារាងទី ១ ខាងក្រោម ផ្តល់លំអិតនៃដំណើរការ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ប្រឈមនឹងលទ្ធផលរបស់គម្រោង

**តារាងទី ១: សង្ខេប — ដំណើរការប្រឈមជាមួយលទ្ធផល គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន**

| **ការអភិវឌ្ឍន៍ គោលបំណង_លទ្ធផល** | **ផលប៉ះពាល់_ សន្ទស្សន៍នៃលទ្ធផល** | **ដំណើរការ** |
|---|---|---|
| ការផ្តល់អទិភាពគម្រោងហេថារចនាសម្ព័ន និងផលប្រយោជន៍សាធារណនៅឃុំ-សង្កាត់ | អាត្រាសេដ្ឋកិច្ចដែលទទួលបានវិញពីអនុគម្រោង>១២ | ការអង្កេតសង្គមសេដ្ឋកិច្ចនៃមូលនិធិឃុំ-សង្កាត់លើគម្រោងផ្លូវ ថ្នល់ ត្រូវបានធ្វើដោយសន្និដ្ឋានថា លទ្ធផលនៃគម្រោងផ្លូវថ្នល់ ក្រោម គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន មានលក្ខណៈ |

| | | |
|---|---|---|
| | | ខ្វះខ្នាយ សំរាប់ធ្វើការវាស់វែង ។ ការសិក្សាលើការទទួលមកវិញពីការវិនិយោគ សន្និដ្ឋានថា អាចទទួលយកបាន |
| ពង្រឹងប្រព័ន្ធវិមជ្ឈការអភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម | ចំណេះដឹង អកប្បកិរិយា ជំនឿ និងការអនុវត្តន៍ (KABP) លើអភិបាលកិច្ចល្អ ត្រូវបានកែលំអនៅទីបញ្ចប់នៃគម្រោង | ការសិក្សាលើ ចំណេះដឹង អកប្បកិរិយា ជំនឿ និងការអនុវត្តន៍ នៅឆ្នាំ ២០០៤ បង្ហាញថាមានការកើនឡើងលើការយល់ដឹង ទូទៅ និងការចាប់អារម្មណ៍លើ KABP ។ ការសិក្សាលើគណនេយ្យភាព ការទទួលបាន និងការឆ្លើយតប បញ្ចប់ក្នុងឆ្នាំ ២០០៨ បង្ហាញចំណុចដែលត្រូវស្រាវជ្រាវបន្តដោយលទ្ធផលមិនអាចផ្តល់ការសន្និដានបាន ។ |
| | ការដេញថ្លៃប្រសើរឡើង និងការអនុវត្តន៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យបានត្រូវទទួលយក និងប្រើប្រាស់សំរាប់មូលនិធិ ឃុំ-សង្កាត់ នៅទីបញ្ចប់នៃគម្រោង | PIM ជាឧបករណ៍សំខាន់ សំរាប់កែលំអការដេញថ្លៃ និងគ្រប់គ្រងថវិកា ។ ភីម ត្រូវបានប្រើប្រាស់ នៅតាមឃុំ ដែលស្ថិតនៅក្រោមគម្រោង វិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន |
| | របាយការណ៍បានប្រសើរឡើង ការផ្សព្វផ្សាយ និងនិតិវិធីចាត់ចែងការប្តឹងតវ៉ា ត្រូវបានប្រើប្រាស់ នៅតាមឃុំ-សង្កាត់ នៅទីបញ្ចប់នៃគម្រោង | ប្រអប់គណនេយ្យភាពសំរាប់ការតវ៉ាលើការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មិនត្រូវបានប្រើប្រាស់ដូចបានរំពឹងទុក ។ |

| ផ្នែកទី១: ផែនការមូលដ្ឋាន និង ការវិនិយោគទុន | | |
|---|---|---|
| ១.១ ផែនការអភិវឌ្ឍន៍ឃុំ និងផែនកាវិនិយោគឃុំ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំងអទិភាព តាមរយៈដំណើរការចូលរួមធ្វើផែនការ ។ | ការណែនាំធ្វើផែនការឆ្លុះបញ្ចាំង ដែលដាក់បញ្ចូល និងដំណើរនៃការចូលរួម នៅចុងឆ្នាំ ២០០៨ ដែលរួមបញ្ចូល ១.តុល្យភាពតំណាងយេនឌ័រនៅតាមភូមិក្នុងគណកម្មាធិការផែនការ និងថវិកា ២.ការចូលរួមដោយមានប្រសិទ្ធភាព រួមបញ្ចូលស្ត្រី និងជនជាតិភាគតិចក្នុងដំណើរធ្វើផែនការ និង ៣.ការចែកព័តិមានយ៉ាងទូលំទូលាយពីដំណើរការធ្វើផែនការ និងលទ្ធផល | ដំណើរការត្រួតពិនិត្យបញ្ជីលើការធ្វើផែនការមិនទាន់បានបញ្ចប់ |
| | ការរៀបចំ ផែនការអភិវឌ្ឍន៍ឃុំ និងផែនកាវិនិយោគទុនឃុំ បានធ្វើតាមឯកសារណែនាំដែលបានកែលំអរួច និងឆ្លុះបញ្ចាំងអទិភាពឃុំ ៨០ភាគរយនៅទីបញ្ចប់នៃគម្រោង | ដំណើរការត្រួតពិនិត្យបញ្ជីលើការធ្វើផែនការមិនទាន់បានបញ្ចប់ |
| ១.២ ថវិកាឃុំ-សង្កាត់ឆ្លុះបញ្ចាំងនៅក្នុងផែនកាវិនិយោគឃុំទាន់ពេលវេលា | >៥០ភាគរយនៃថវិកាឃុំ-សង្កាត់រៀបចំដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងត្រូវបានយល់ព្រមដោយអភិបាលខេត្តនៅចុងខែមករា និង៩៥ភាគរយនៅចុងខែកុម្ភៈរៀងរាល់ឆ្នាំ នៅទីបញ្ចប់នៃគម្រោង | ទិន្នន័យមាននៅក្នុង PID តែការវិភាគមិនទាន់បានធ្វើនៅ ឡើយ |
| | >៩៥ភាគរយនៃការវិនិយោគរួមបញ្ចូលក្នុងថវិកាឃុំ-សង្កាត់ បានឆ្លុះបញ្ចាំងអទិភាពនៅក្នុង ផែនការ | ដំណើរការត្រួតពិនិត្យបញ្ជីមិនទាន់បានធ្វើនៅឡើយ |

| | | |
|---|---|---|
| | វិនិយោគទុនឃុំ | |
| ១.៣ អទិភាពនៃការវិនិយោគឃុំ-សង្កាត់ ដែលផ្តល់ថវិកាតាមរយៈមូលនិធិឃុំ-សង្កាត់ ត្រូវបានអនុវត្តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ តាមប្រព័ន្ធ និងនិតិវិធីដែលបានព្រមព្រៀងរួម | ៣៩០០អនុគម្រោងនៅចុងឆ្នាំ ២០០៦ និង៧៥០០អនុគម្រោង នៅទីបញ្ចប់នៃគម្រោងដែលបាន អនុវត្តនៅឃុំគោលដៅ | ៣៩៥១អនុគម្រោងនៅចុងឆ្នាំ ២០០៦ ៤៨៨០អនុគម្រោង នៅចុងឆ្នាំ២០០៧ (ផ្នែកឥណទាន) ១៦៧៩អនុគម្រោង សំរាប់ឆ្នាំ ២០០៧ និង២០០៨ សំរាប់ផ្នែកជំនួយគ្មានសំណង |
| | >៩០ភាគរយនៃអនុគម្រោងទទួលបានការពេញចិត្តលើគុណភាពបច្ចេកទេស | ការត្រួតពិនិត្យបច្ចេកទេសបង្ហាញគុណភាពផ្លូវថ្នល់អាចទទួលយកបាន ប៉ុន្តែលទ្ធផលគម្រោងផ្គត់ផ្គង់ទឹក និងស្រោចស្រព មិនអាចទទួលយកបាន ។ យោលតាមក្រុមវាយតម្លៃពាក់កណ្តាលគម្រោងមានគម្រោងតិចជាង៩០ភាគរយនៃអនុគម្រោងទទួលបានការពេញចិត្តលើផ្នែកបច្ចេកទេស ប៉ុន្តែការសន្និដ្ឋាននេះ ផ្អែកលើព័ត៌មានខ្លីៗ និងការសង្កេតប៉ុណ្ណោះ ។ |
| **ផ្នែកទី២: ការគាំទ្រគោលនយោបាយ និងការគ្រប់គ្រងគម្រោង** | | |
| ២.១ ស្ថាបនឃុំ ខេត្ត និងជាតិ ត្រូវបានបំពាក់តំរូវការចាំបាច់ដើម្បីអនុវត្តផែនការវិមជ្ឈកា ថវិកា ការគ្រប់គ្រង និងត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់គម្រោង | ឃុំដែលបានចូលរួមមួយរយភាគរយ និងបុគ្គលិកគាំទ្រថ្នាក់ក្រោម ជាតិទទួលបានការបណ្តុះបណ្តាលលើការធ្វើផែនការ ការអនុវត្តន៍ ការដេញថ្លៃ និងប្រព័ន្ធហិរញ្ញវត្ថុ និងនិតិវិធី នៅក្នុងឆ្នាំទី១ នៃការអនុវត្តន៍គម្រោង | តាមរយៈព័ត៌មានដែលមាន មិនអាចកំណត់លើចំណុចនេះបានទេ |

| | | |
|---|---|---|
| | យ៉ាងហោចណាស់ក៏ត្រូវមានបុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ក្រោមជាតិចុះទៅតាមមូលដ្ឋានម្តងក្នុងមួយខែ | តាមរយៈព័តិដែលមាន មិនអាចកំណត់លើចំណុចនេះបានទេ ។ ព័តិទទួលបាននៅពេលចុះតាមខេត្តរបស់ក្រុមវាយតម្លៃពាក់កណ្តាលគម្រោង បង្ហាញថា TSO បានចុះទៅតាមឃុំតិចតួចណាស់ ប៉ុន្តែមានការចុះទៅតាមឃុំញឹកញាប់ដែរនៃក្រុម DFT |
| | PST/NCDD មានរថយន្តធ្វើដំណើរ កុំព្យូទ័រ និងម៉ាស៊ីនថតចម្លងនៅចុងឆ្នាំទី១ | មធ្យោបាយទាំងនេះបានមកដល់ទីកន្លែងនៅ ឆ្នាំទី២ |
| | អង្គភាពគណកម្មាធិការប្រតិបត្តិ និងរតនាគារខេត្តទទួលបានរថយន្ត កុំព្យូទ័រ ទោចក្រយានយន្ត ម៉ាស៊ីនថតចម្លង ទូក គ្រឿងសង្ហារឹម និងម៉ាស៊ីនភ្លើង នៅចុងឆ្នាំទី១ | មធ្យោបាយទាំងនេះបានមកដល់ទីកន្លែងនៅ ឆ្នាំទី២ |
| | PST និងអាគារគណកម្មាធិការប្រតិបត្តិ ត្រូវបានសាងសង់ ជួសជុលនៅចុងឆ្នាំ ២០០៨ | បានសាងសង់ ជួសជុលនៅចុងឆ្នាំ២០០៩ |
| ២.២ កម្មវិធីអភិវឌ្ឍ និងលទ្ធិប្រជាធិបថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត | កម្មវិធីជាតិ SNDD ស្របជាមួយយុទ្ធសាស្ត្រ វិមជ្ឈកា និងសហវិមជ្ឈកា ត្រូវបានបេង្កីតឡើងនៅខែមករា ឆ្នាំ២០០៩ | កម្មវិធីជាតិបង្កើតឡើងនៅខែ កញ្ញា ឆ្នាំ២០០៩ |
| ២.៣ យុទ្ធសាស្ត្រសារពើពន្ធវិមជ្ឈកាស្របតាមយុទ្ធសាស្ត្រវិមជ្ឈកា និង | កែសម្រួលអនុក្រិត្យបង្កើតមូលនិធិឃុំ-សង្កាត់សំរាប់ឆ្នាំ ២០០៨-២០១០ | អនុក្រិត្យចេញនៅ ខែកក្កដា ឆ្នាំ ២០០៧ |

| | | |
|---|---|---|
| សហវិមជ្ឈការ ហើយព្រមព្រៀងតាមការកែទម្រង់ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបង្កើតឡើង និងអនុវត្ត | នៅចុងឆ្នាំ២០០៧ | |
| | ឃុំទទួលបានថវិកាស្មើនឹងថវិកាវិភាជន៍តាមរយៈពេលកំណត់ព្រមព្រៀងនៃសាច់ប្រាក់ដែលត្រូវបានបញ្ចេញនៅឆ្នាំ ២០០៥ ជាបន្តបន្ទាប់ ។ | ទិន្នន័យមាននៅ PID តែការវិភាគមិនទាន់មាន |
| | ការបង្កើតយុទ្ធសាស្ត្រដើម្បីបង្កើនការទទួលបានប្រាក់ចំណូលដោយឃុំផ្ទាល់ខ្លួន នៅពាក់កណ្តាលឆ្នាំ ២០០៧ ។ និយតកម្មត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីសម្របសម្រួល ការប្រមូលប្រាក់នៅឆ្នាំ ២០០៨ ហើយការអនុវត្តន៍ឬជាយុទ្ធសាស្ត្រចាប់ផ្តើមនៅឆ្នាំ ២០០៩ ។ | ទិន្នន័យមាននៅ PID តែការវិភាគមិនទាន់មាន |